ក្រសួងអប់រំ យុវជន និងកីឡា



# ក្លឹបប្រវត្តិសាស្ត្រ

២០២៣

ឯកសារបោះពុម្ពនេះត្រូវបានរៀបចំចងក្រងឡើងដោយគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USE-SDP-2) របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រោមកិច្ចសហការជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដើម្បីចងក្រងជាឯកសារនវានុវត្តក្នុងការបង្កើត និងការដឹកនាំក្លឹប។

**រូបភាពក្របសៀវភៅ:** រចនាដោយលោក អឿ សារីន អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

© ក្រសួង អ.យ.ក ២០២២

# មាតិកា


**បុព្វកថា** ........ iii
**១. សេចក្តីផ្តើម** ........ 1
**២. វត្ថុបំណង** ........ 1
**៣. សម្ភារ** ........ 1
**៤. ដំណើរការអនុវត្តសកម្មភាព** ........ 2
៤.១ គោលការណ៍រៀបចំក្លឹប ........ 2
៤.១.១ ការស្ម័គ្រចិត្ត ........ 2
៤.១.២ ទំហំ ........ 2
៤.១.៣ កម្រិតថ្នាក់គោលដៅ ........ 3
៤.១.៤ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស និងការតម្រង់ទិស ........ 3
៤.១.៥ ការបែងចែកភារកិច្ច ........ 4
៤.១.៦ ការកំណត់ផែនការ ........ 4
៤.១.៧ ការកំណត់ធនធាន ........ 5
**៤.២ សកម្មភាពស្នើឡើង ........ 6**
៤.២.១ ទស្សនកិច្ចសិក្សា ........ 6
៤.២.២ សកម្មភាពស្រាវជ្រាវប្រវត្តិសាស្ត្រតាមរយៈសម្ភាសន៍ ........ 13
៤.២.៣ ការតាំងពិព័រណ៌ស្នាដៃក្នុងបណ្ណាល័យ និងថ្នាក់រៀន ........ 14
៤.២.៤ ការអញ្ជើញវាគ្មិន ........ 18
៤.២.៥ ការបង្កើតខិត្តប័ណ្ណផ្សព្វផ្សាយតំបន់មូលដ្ឋាន ........ 19
៤.២.៦ ការផ្សារភ្ជាប់ក្លឹបជាមួយនឹងការរៀនសូត្ររបស់សិស្សដទៃទៀត ........ 20
**ឧបសម្ព័ន្ធទី១៖ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស និងការតម្រង់ទិស** ........ 21
ឧបសម្ព័ន្ធទី២៖ ការបែងចែកភារកិច្ច ........ 22
ឧបសម្ព័ន្ធទី៣៖ ការកំណត់ផែនការ ........ 23
ឧបសម្ព័ន្ធទី៤៖ ការកំណត់ធនធាន ........ 24

# បុព្វកថា

ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការអប់រំបានបណ្តុះនូវមូលធនមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា កាយសម្បទា និងមនសិការវិជ្ជាជីវៈសម្រាប់សង្គមជាតិ។ ក្នុងបរិការណ៍នេះ ក្រសួងអប់រំ យុវជន និងកីឡា មានសេចក្តីសោមនស្សរីករាយក្នុងការចេញផ្សាយ នូវសៀវភៅក្លឹបសិក្សាបន្ថែមសម្រាប់ប្រើប្រាស់ក្នុងសាលាមធ្យមសិក្សាសាធារណៈ។

សៀវភៅនេះ មានកម្មវត្ថុសំខាន់ គឺផ្តល់នូវទិដ្ឋភាពថ្មីៗ ដល់សិស្សានុសិស្សទាំងអស់ ដែលត្រូវការសិក្សាបន្ថែមក្រៅពីការរៀននៅក្នុងថ្នាក់រៀន។ ការបង្កើតក្លឹបសិក្សាបន្ថែម គឺជាការងារស្ម័គ្រចិត្ត ដែលនឹងត្រូវជ្រើសរើសយកទៅអនុវត្តតាមតម្រូវការរបស់សាលាមធ្យមសិក្សាសាធារណៈ ក្នុងការផ្តល់សេវាផ្នែកអភិវឌ្ឍបុគ្គលឱ្យកាន់តែសម្បូរបែបដល់សិស្សតាមប្រធានបទ ដែលសិស្សចាប់អារម្មណ៍។ ការផ្តល់សេវាផ្នែកនេះនឹងមានផលជះដល់ការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់យុវជនកម្ពុជាឱ្យរស់នៅទាន់សម័យកាលជឿនលឿន និងការឈានឡើងរបស់កម្ពុជាជាទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ។

ទន្ទឹមនេះ ការបង្កើតក្លឹបនេះ ទាមទារឱ្យមានក្របខណ្ឌច្បាស់លាស់សម្រាប់ការណែនាំសិស្ស រចនាសម្ព័ន្ធប្រតិបត្តិការ តួនាទី និងភារកិច្ច សម្រាប់គ្រូដឹកនាំ និងសកម្មភាពគំរូជាក់ស្តែង ដែលពាក់ព័ន្ធទៅនឹងប្រធានបទដែលមាន។ សៀវភៅនេះ បានផ្តល់នូវរចនាសម្ព័ន្ធច្បាស់លាស់ ដល់គ្រូបង្រៀននិងអ្នកគ្រប់គ្រងសាលារៀនផ្តល់ឱកាសសិក្សាបន្ថែមដល់សិស្ស ដែលចាប់អារម្មណ៍ពិសេសទៅលើជំនាញបន្ថែមណាមួយ។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងផ្តល់នូវប្រយោជន៍ដល់មន្ត្រីអប់រំ និងគ្រូបង្រៀននៅមូលដ្ឋានក្នុងការរៀបចំក្លឹបសិក្សាសម្រាប់សិស្ស ប្រកបដោយប្រសិទ្ធភាពតាមជំនាញបន្ថែមនីមួយៗនិងតាមប្រធានបទជាច្រើនដទៃទៀតក្នុងការរួមចំណែកកសាងនិងអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

## ១. សេចក្ដីផ្ដើម

ឯកសារនេះបង្កើតឡើង ដើម្បីជួយដល់សាលាមធ្យមសិក្សាក្នុងការផ្ដល់ឱកាសដល់សិស្សឱ្យសិក្សាស្វែងបន្ថែមទៀតពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ ឱកាសនោះ នឹងផ្ដល់ការយល់ដឹងដល់សិស្សឱ្យកាន់តែទូលំទូលាយពីមេរៀនប្រវត្តិសាស្ត្រដែលមិនត្រូវបានដាក់បញ្ចូលក្នុងសៀវភៅសិក្សាគោល។ ការយល់ដឹងរបស់សិស្សផ្នែកប្រវត្តិសាស្ត្រនេះ នឹងបង្កើនការរៀនរបស់ពួកគេបានដល់ទៅពីរបីរបៀបដូចជា វាអាចឱ្យពួកគេដឹងពីសកម្មភាពដែលបានកើតឡើងក្នុងពេលអតីតបន្តរហូតមកដល់បច្ចុប្បន្ន។ វាជួយឱ្យពួកគេបង្កើនមោទនភាពពីទីកន្លែងណាមួយ យល់ដឹងពីអត្តសញ្ញាណអ្វីមួយដែលទាក់ទងនឹងតំបន់ណាមួយ យល់ដឹងពីកន្លែងនោះ ហើយអាចដឹងថាតើកន្លែងនោះនឹងក្លាយទៅជាយ៉ាងណានៅពេលអនាគត។ ឱកាសដ៏ពិសេសនេះ នឹងធ្វើឱ្យការរៀនសូត្រកាន់តែមានលក្ខណៈគួរឱ្យចាប់អារម្មណ៍ថែមទៀត និងប្រកបដោយភាពទាក់ទាញអារម្មណ៍ស្របតាមបញ្ញត្តិសាលាកុមារមេត្រី។ ដើម្បីផ្ដល់បទពិសោធន៍បែបនេះ សាលារៀនគួររៀបចំក្រុមសិស្សជាលក្ខណៈក្រៅផ្លូវការមួយក្នុងក្លឹបមុខវិជ្ជាប្រវត្តិសាស្ត្រ(ក្លឹបប្រវត្តិសាស្ត្រ) ស្ថិតក្រោមការដឹកនាំរបស់គ្រូម្នាក់ ឬច្រើននាក់។ សមាជិកភាពដែលចូលរួមបង្កើតក្រុមនេះ គឺជាការស្ម័គ្រចិត្ត។ គោលបំណងក្លឹប គឺរៀបចំសកម្មភាពតាមរចនាសម្ព័ន្ធដែលតម្រូវឱ្យសិស្សមានទំនាក់ទំនងយ៉ាងជិតស្និទ្ធលើការសិក្សាស្រាវជ្រាវពីប្រវត្តិតំបន់របស់ពួកគេ។ សកម្មភាពបែបនេះ អាចជាការស្រាវជ្រាវតាមរយៈការនិយាយផ្ទាល់មាត់ក៏បាន (ឧ. ការសម្ភាសជាមួយមនុស្សមានបទពិសោធន៍ពីប្រធានបទមួយចំនួន) ធ្វើទស្សនកិច្ចសិក្សា ការរៀនបង្កើតផែនទី ឬការសរសេររបាយការណ៍ពីប្រធានបទណាមួយដែលតម្រូវឱ្យធ្វើការស្រាវជ្រាវតាមមូលដ្ឋាន។

★ក្លឹបគឺៈ ការប្រមូលផ្ដុំនៃមនុស្សមួយក្រុមដោយមានគោលដៅរួម ឬមានចំណង់ចំនូលចិត្តដូចគ្នាដើម្បីធ្វើកិច្ចការរួម និងផលប្រយោជន៍រួមមួយ ។

## ២. វត្ថុបំណង

- សិស្សមានឱកាសរៀនបន្ថែមពីប្រវត្តិសាស្ត្រដែលទាក់ទងនឹងសហគមន៍របស់ពួកគេ។
- គ្រូអាចប្រើឯកសារនេះដើម្បីជួយសិស្សឱ្យចេះរៀបចំសកម្មភាពតាមរចនាសម្ព័ន្ធដែលជំរុញឱ្យពួកគេយល់ដឹងកាន់តែច្រើនពីប្រវត្តិសាស្ត្រតំបន់របស់ពួកគេ។

## ៣. សម្ភារ

- សម្ភារទាក់ទងនឹងការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រ (ឧ. សៀវភៅ ផែនទី តុ ។ល។)
- សម្ភារសិក្សា ប៊ិកសម្រាប់សរសេររបាយការណ៍ និងធ្វើបទបង្ហាញ
- សម្ភារសម្រាប់ដាក់តាំងពិព័រណ៍ ផែនទី ។ល។
- ថវិកាសម្រាប់ធ្វើដំណើរទស្សនកិច្ចសិក្សា

- ថវិកាសម្រាប់សិស្ស និងគ្រូ ដើម្បីរៀបចំការប្រជុំនៅស្នាក់ការកណ្ដាលរបស់សាលារៀន។

## ៤. ដំណើរការអនុវត្តសកម្មភាព

### ៤.១ គោលការណ៍រៀបចំក្លឹប

ការបង្កើតក្លឹបប្រវត្តិសាស្ត្រ ត្រូវធ្វើឡើងដោយមានគោលការណ៍អនុវត្តសំខាន់ៗមួយចំនួនដូចខាងក្រោម៖

#### ៤.១.១ ការស្ម័គ្រចិត្ត

អ្នកសម្របសម្រួលសាលារៀនត្រូវយល់ថា ការចូលរួមក្នុងក្លឹបប្រវត្តិសាស្ត្រនេះ គឺមិនមែនសម្រាប់សិស្សគ្រប់គ្នាទេ ហើយក៏មិនមែនជាការបង្ខិតបង្ខំសិស្សឱ្យចូលរួមក្នុងក្លឹបនេះដែរ។ សិស្សមានចំណូលចិត្តខុសៗគ្នា ដូចនេះអ្នកសម្របសម្រួលគួរជួយសម្រួលដល់បញ្ហានេះឱ្យបានសមរម្យស្របតាមបញ្ញត្តិសាលាកុមារមេត្រី។ ឧទាហរណ៍ គ្រូអាចបង្កើតក្លឹបនេះក្នុងពេលតែមួយ ខណៈពេលដែលក្លឹបដទៃទៀតត្រូវបានបង្កើតផងដែរ។ វាមានន័យថា មានគ្រូផ្សេងៗទៀតកំពុងបង្កើតក្លឹបដទៃទៀតដែរ ដូចជាក្លឹបវិទ្យាសាស្ត្រ ឬក្លឹបនិពន្ធជាដើម។ គ្រូគួរទុកពេលឱ្យសិស្សជ្រើសរើសក្លឹបដែលពួកគេចង់ចូលរួមឱ្យបានទូលំទូលាយ និងត្រូវមើលថាតើពួកគេមានពេលវេលា និងចំណូលចិត្តក្នុងការចូលរួមក្លឹបដែរឬទេ។

ដូចគ្នានេះដែរ ថ្នាក់ដឹកនាំក៏មិនត្រូវបង្ខំគ្រូឱ្យរៀបចំក្លឹបប្រវត្តិសាស្ត្រនេះដែរ។ ការពេញចិត្ត និងការចាប់អារម្មណ៍របស់គ្រូចំពោះការដឹកនាំក្លឹបប្រវត្តិសាស្ត្រ ជាការចាំបាច់ក្នុងការឈានទៅដល់ភាពជោគជ័យរបស់ក្លឹប ដូច្នេះថ្នាក់ដឹកនាំគួរយល់ថា លទ្ធផលជោគជ័យនឹងពិបាកទទួលបាន ប្រសិនបើបង្ខំគ្រូឱ្យធ្វើសកម្មភាព។ ជាមួយគ្នានេះដែរ គ្រូស្ម័គ្រចិត្តអាចចំណាយពេលផ្ទាល់ខ្លួនរបស់គាត់ខ្លះៗ ដើម្បីធ្វើផែនការសកម្មភាពជាមួយសិស្ស ដូចជាការចូលរួមប្រជុំក្រៅម៉ោងសិក្សា និងការធ្វើដំណើរទស្សនកិច្ចតាមរមណីយដ្ឋានប្រវត្តិសាស្ត្រនានាក្នុងមូលដ្ឋាន។ គណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវពិចារណាលើទម្រង់ការមួយចំនួនទាក់ទងនឹងប្រាក់ឧបត្ថម្ភគ្រូដឹកនាំក្លឹបដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់ថវិកាសកម្មភាពផ្សេងទៀតដូចជា ការបំប៉នសិស្សរៀនយឺត និងកម្មវិធីគេហកិច្ច ជាដើម។

#### ៤.១.២ ទំហំ

ក្លឹបប្រវត្តិសាស្ត្រនេះមានភាពងាយស្រួលក្នុងការគ្រប់គ្រង ពេលធ្វើក្នុងសាលារៀនមួយដោយសារសិស្ស និងគ្រូទាំងអស់ស្ថិតនៅកន្លែងតែមួយ។ ក្នុងករណីខ្លះសាលារៀនមួយចំនួន ដែលនៅក្បែរគ្នាក្នុងតំបន់គោលដៅក៏អាចចូលរួមក្នុងក្លឹបប្រវត្តិសាស្ត្រនេះបានដែរ។ ករណីនោះអាចសាមីសាលារៀនប្រធានកម្រង ដើរតួជាអ្នកសម្របសម្រួល។ ប្រសិនបើមានសាលារៀនមួយចំនួនកំពុងអនុវត្តក្លឹបប្រវត្តិសាស្ត្រ នាយកសាលាពាក់ព័ន្ធទាំងនោះ អាចសម្រេចចិត្តដាក់ធនធានរួមគ្នាសម្រាប់ធ្វើសកម្មភាពដូចជា ទស្សនកិច្ចសិក្សា ពិព័រណ៍

ភាពយន្ត។ល។ ការអនុវត្តសកម្មភាពរួមគ្នា អាចមានអត្ថប្រយោជន៍មួយចំនួនដូចជា ការជៀសវាងធ្វើសកម្មភាពជាន់គ្នា ជាពិសេសករណីដំណើរទស្សនកិច្ចសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ការសម្របសម្រួលក្នុងកម្រិតនេះ ពេលខ្លះអាចជួបបញ្ហាប្រឈម។ នាយកសាលាដែលពាក់ព័ន្ធគួរពិនិត្យមើលកម្រិតចំណាប់អារម្មណ៍ចូលរួមក្នុងក្លឹបប្រវត្តិសាស្ត្រពីសាលារៀនមួយចំនួន ចម្ងាយរវាងសាលារៀន និងការពេញចិត្តរបស់គ្រូដឹកនាំនៅពេលសម្រេចចិត្តថាតើត្រូវរៀបចំក្លឹបរួមគ្នា ឬដាច់ដោយឡែក។ ក្នុងករណីអនុវត្តសកម្មភាពរួមគ្នាគេត្រូវចាត់ចែងថវិកាដែលចាំបាច់សម្រាប់ការធ្វើដំណើរសម្របសម្រួលកិច្ចប្រជុំអន្តរសាលា។

**៤.១.៣ កម្រិតថ្នាក់គោលដៅ**

ការចូលរួមក្លឹបប្រវត្តិសាស្ត្រ ជាសកម្មភាពមួយដែលលើកដំបូងយើងត្រូវកំណត់ជ្រើសរើសយកសិស្សពេញវ័យ។ នៅពេលដែលសាលាមានបទពិសោធច្រើនពីការរៀបចំក្លឹបនេះហើយ គ្រូអាចធ្វើការសាកល្បងរៀបចំសកម្មភាពក្លឹបដែលសមរម្យទៅនឹងសិស្សតូចៗបាន។ ប៉ុន្តែសម្រាប់សាលាមធ្យមសិក្សា ក្លឹបនេះអាចរៀបចំនៅកម្រិតថ្នាក់ទីប៉ុន្មានក៏បាន អាស្រ័យលើលទ្ធភាពរបស់គ្រូ ថាតើគាត់ចាប់អារម្មណ៍ក្នុងការងារនេះឬយ៉ាងណា។

**៤.១.៤ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស និងការតម្រង់ទិស**

ការចូលរួមក្លឹប គឺអាស្រ័យលើការសម្រេចចិត្តរបស់សិស្សផ្ទាល់។ ការវាយតម្លៃចំណាប់អារម្មណ៍សិស្សពីការចូលរួមក្លឹបនេះ គ្រូត្រូវពន្យល់ណែនាំពីអត្ថន័យក្លឹបនោះជាមុនសិន។ ការណែនាំនេះអាចនិយាយផ្ទាល់មាត់ទៅកាន់សិស្សក្នុងថ្នាក់ ឬអាចសរសេរបិទនៅទីធ្លាបរិវេណសាលា ឬយើងអាចប្រើវិធីទាំងពីរនេះតែម្តង។ សេចក្តីណែនាំទាំងអស់រួមមានចំណុចដូចខាងក្រោមនេះ៖

- **វត្ថុបំណង៖** ដើម្បីបង្កើនការយល់ដឹងរបស់សិស្សពីប្រវត្តិសាស្ត្រក្នុងមូលដ្ឋាន។
- **សកម្មភាព៖** ធ្វើដំណើរទស្សនកិច្ចសិក្សា ការតាំងពិព័រណ៍ប្រវត្តិសាស្ត្រ ការស្រាវជ្រាវជាក្រុមតាមរយៈសម្ភាសន៍ និងការអានសៀវភៅ។ល។
- **ការវាយតម្លៃ៖** ពុំមានការវាយតម្លៃ ឬដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ គឺសិស្សចូលរួមក្នុងសកម្មភាពក្លឹបដោយការពេញចិត្តរបស់ពួកគេ ពុំមែនដោយសារការបង្ខំឡើយ។
- **ការចូលរួម៖** សមាជិកភាពក្លឹបចូលរួមដោយស្ម័គ្រចិត្ត។
- **ការប្រជុំ៖** ការប្រជុំសាមញ្ញ (២សប្តាហ៍ម្តង) ដើម្បីពិភាក្សាពីសកម្មភាពដែលបានគ្រោងទុក។ ចំណុចខាងលើនេះ ត្រូវអនុវត្តក្រៅម៉ោងសិក្សា ឬថ្ងៃឈប់សម្រាក។

អនុវត្តតាមសេចក្តីណែនាំនេះ គ្រូត្រូវសួរសិស្សថាតើពួកគេចាប់អារម្មណ៍ក្នុងការចូលរួមក្លឹបនេះឬទេ ហើយកំណត់ឱ្យបានពីកម្រិតនៃការចាប់អារម្មណ៍របស់ពួកគេ។ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស គ្រូត្រូវប្រើទម្រង់ដែលមានក្នុង**ឧបសម្ព័ន្ធទី១**។ ទម្រង់នេះមានប្រយោជន៍ ពីព្រោះវាទប់ស្កាត់មិនឱ្យមានការគាប

សង្កត់ និងបង្ខំសិស្សឱ្យនិយាយថា យល់ព្រម ឬ មិនយល់ព្រម ជាពិសេសនៅចំពោះមុខគ្រូ សិស្សបង្ហាញនូវភាពមិនស្មោះត្រង់។ អាស្រ័យហេតុនេះ គ្រូត្រូវផ្តល់ពេលឱ្យសិស្សរយៈពេលពី ១០ ទៅ ១៥នាទី ដើម្បីឱ្យពួកគេធ្វើការសម្រេចចិត្តមុនពេលបំពេញទម្រង់ និងមុនពេលប្រគល់ទម្រង់នោះជូនគ្រូវិញ។

### ៤.១.៥ ការបែងចែកភារកិច្ច

នៅពេលមានកិច្ចប្រជុំក្លឹបជាលើកដំបូង គ្រូដឹកនាំក្លឹប ត្រូវជ្រើសរើសសមាជិកមួយចំនួនដើម្បីទទួលខុសត្រូវលើកិច្ចការនានា។ ការជ្រើសរើសនេះ ធ្វើឡើងដោយការបោះឆ្នោត ឬ តាមរយៈការលើកដៃ។ តួនាទីគឺមិនទៀងទាត់ទេ រួមមាន ១)ប្រធាន ២)អនុប្រធាន និង ៣)ហិរញ្ញិក។ ប្រសិនបើមានសិស្សច្រើននាក់នៅក្នុងក្លឹប (ឧ. ១៥នាក់ ឬច្រើនជាងនេះ) ចាំបាច់ត្រូវមានប្រធានក្រុម ១នាក់ សម្រាប់សម្របសម្រួលសិស្ស ៣ ឬ ៤នាក់នោះ។ ការទទួលខុសត្រូវនេះបានភ្ជាប់ជូនក្នុង**ឧបសម្ព័ន្ធទី២**។ គ្រូដឹកនាំក្លឹបត្រូវពន្យល់ និងបង្ហាញដល់សមាជិកក្លឹបទាំងអស់។ នៅក្នុងជំហានដំបូងនៃសកម្មភាពក្លឹប គ្រូដឹកនាំត្រូវទទួលខុសត្រូវក្នុងការចូលរួមចំណែកជួយសមាជិកក្លឹប ដើម្បីឱ្យពួកគេមានទំនាក់ទំនងគ្នា និងបំពេញតួនាទីបានល្អ។ ជាមួយគ្នានោះដែរ គ្រូដឹកនាំត្រូវខិតខំប្រឹងប្រែងបំពេញភារកិច្ចឱ្យបានល្អ ដើម្បីជួយសិស្សឱ្យទទួលបានបទពិសោធន៍ការងារល្អប្រសើរ។

### ៤.១.៦ ការកំណត់ផែនការ

កិច្ចការមួយក្នុងចំណោមកិច្ចការទាំងឡាយដែលក្លឹបត្រូវធ្វើគឺ ការរៀបចំផែនការសកម្មភាពដែលបានស្នើសុំក្នុងរយៈពេល១ត្រីមាស។ ទម្រង់ផែនការសកម្មភាពក្លឹបមានលក្ខណៈសមស្របពីមួយសប្តាហ៍ទៅមួយសប្តាហ៍ក្នុងខែនីមួយៗ ដូចបានភ្ជាប់ជូនក្នុង**ឧបសម្ព័ន្ធទី៣**។ មុនពេលធ្វើផែនការគ្រូគួរពិនិត្យមើលថាតើសកម្មភាពណាដែលអាចធ្វើទៅបាន ហើយកំណត់យកគម្រោង១ ឬ២ ដែលក្លឹបនឹងអនុវត្តក្នុងត្រីមាសនីមួយៗ។ ឧទាហរណ៍ ក្លឹបចង់ឱ្យសិស្សសិក្សាពីប្រាសាទនៅក្នុងតំបន់មួយ។ មុនពេលទៅមើលប្រាសាទនោះ គ្រូអាចបរិយាយពីប្រវត្តិខ្លះៗរបស់ប្រាសាទ និងណែនាំពីអ្វីដែលសិស្សត្រូវធ្វើនៅពេលទៅដល់ដូចជា ថាតើប្រាសាទនោះត្រូវបានកសាងនៅឆ្នាំណា (ដោយពិនិត្យមើលបែបបទអក្សរសិលាចារិក ឬសាកសួរព័ត៌មានពីចាស់ទុំនៅមូលដ្ឋាននោះផ្ទាល់) ទីតាំង និងរចនាបថ ប្រាសាទ ការថតរូបក្បាច់ចម្លាក់សំខាន់ៗ ការផ្តិតអក្សរសិលាចារិក និងការអានពីប្រវត្តិរបស់ប្រាសាទនោះជាមុន។ គ្រូអាចពន្យល់សិស្សពីរបៀបនៃការពិនិត្យមើលវត្ថុទាំងនោះផងដែរ។ សូមមើល**ឧបសម្ព័ន្ធទី៤**។ នៅពេលការសិក្សាស្រាវជ្រាវបញ្ចប់ ក្លឹបត្រូវរៀបចំការដាក់តាំងពិព័រណ៍ក្នុងបណ្ណាល័យ ឬថ្នាក់រៀន ព្រមទាំងធ្វើបទបង្ហាញពីអ្វីដែលបានស្រាវជ្រាវនោះទៅដល់សិស្សដទៃទៀតដែលមិនមែនជាសមាជិករបស់ក្លឹប។ គ្រប់សកម្មភាពទាំងនេះ គួរតែសរសេរទុកនៅក្នុងផែនការ។ សូមមើលឧទាហរណ៍ក្នុងតារាងខាងក្រោម៖

- តារាងទី១៖ ការកំណត់ផែនការ

ត្រីមាសទី១

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១. កិច្ចប្រជុំទី១៖ ស្វែងរកគម្រោងស្រាវជ្រាវប្រវត្តិសាស្រ្ត | √ | | | | | | | | | | | |
| ២. កិច្ចប្រជុំទី២៖ ការសិក្សាស្រាវជ្រាវលើកដំបូង (ការរៀនពីអក្សរខ្មែរបុរាណ) | | √ | | | | | | | | | | |
| ៣. កិច្ចប្រជុំទី៣៖ ការសិក្សាស្រាវជ្រាវលើកដំបូង (ការរៀនពីរចនាបថប្រាសាទ ទីតាំង ផែនទី។ល។) | | | | √ | | | | | | | | |
| ៤. ដំណើរទស្សនកិច្ចលើកដំបូងទៅកាន់ប្រាសាទបុរាណក្នុងតំបន់ | | | | √ | | | | | | | | |
| ៥. ដំណើរទស្សនកិច្ចលើកទី២ ទៅកាន់ប្រាសាទបុរាណក្នុងតំបន់។ | | | | | √ | | | | | | | |
| ៦. កិច្ចប្រជុំទី៤៖ រៀបចំផែនការតាំងពិព័រណ៍ ដើម្បីឱ្យដឹង ថាតើដំណើការស្រាវជ្រាវនោះយ៉ាងដូចម្តេច? រៀបចំកិច្ចការ ហើយត្រូវសម្រេចចិត្តថាតើនរណាត្រូវធ្វើកិច្ចការអ្វី? | | | | | | √ | | | | | | |
| ៧. ជួបជុំគ្នាដើម្បីរៀបចំការតាំងពិព័រណ៍ក្នុងបណ្ណាល័យ | | | | | | | √ | √ | | | | |
| ៨. ធ្វើបង្ហាញពីប្រាសាទដល់សិស្សដទៃទៀត | | | | | | | | | √ | | | |

**៤.១.៧ ការកំណត់ធនធាន**

ដើម្បីធ្វើឱ្យសកម្មភាពក្លឹបប្រកបដោយប្រសិទ្ធភាពចាំបាច់ត្រូវមានធនធានមួយចំនួនដូចជា សម្ភារកន្លែងប្រជុំ(បណ្ណាល័យ ឬថ្នាក់រៀនទំនេរ) សៀវភៅនៅក្នុងបណ្ណាល័យសម្រាប់ការសិក្សាស្រាវជ្រាវ បន្ទប់កុំព្យូទ័រសម្រាប់សរសេររបាយការណ៍ (ប្រើចំពោះថ្នាក់មធ្យមសិក្សា) និងធនធានថវិកា។ ធនធានប្រើប្រាស់ជាតម្រូវការសម្រាប់អនុវត្តសកម្មភាពជាក់ស្តែងដូចខាងក្រោម៖

- ក្រដាសសម្រាប់កត់ត្រា ឬសរសេររបាយការណ៍ (សម្រាប់ក្រុមទាំងអស់)
- ក្រដាសផ្ទាំងធំសម្រាប់គូផែនទី ធ្វើការដាក់តាំងពិព័រណ៍ និងប្រជុំ
- ហ្វឺតសម្រាប់សរសេររៀបចំការតាំងពិព័រណ៍
- ថវិកាសម្រាប់ធ្វើដំណើរទស្សនកិច្ចសិក្សា
- ម៉ាស៊ីនថតរូប
- ថវិកាសម្រាប់ចំណាយផ្សេងៗ

ថវិកាក្លឹបត្រូវបានរៀបចំឡើងដោយគណៈកម្មការគ្រប់គ្រងសាលាក្នុងពេលដំណើរការរៀបចំផែនការ

ប្រចាំឆ្នាំដែលធ្វើឡើងនៅដើមឆ្នាំសិក្សានីមួយៗ។ សូមមើលក្នុង**ឧបសម្ព័ន្ធទី៤**។

## ៤.២ សកម្មភាពស្នើឡើង

សកម្មភាពនានាជាច្រើនដែលក្លឹបអាចរៀបចំកែលម្អកិច្ចការដើម្បីមើលទៅឱ្យចាប់អារម្មណ៍ និងមានលក្ខណៈគិតស៊ីជម្រៅសម្រាប់សិស្ស ហើយសកម្មភាពដែលបានផ្ដល់ឱ្យខាងក្រោមនេះ គឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។ គ្រូ និងសមាជិកក្លឹប អាចបញ្ចេញយោបល់ផ្ទាល់ខ្លួនពីអ្វីដែលពួកគេចង់ធ្វើដើម្បីពង្រីកនូវឱកាសរៀនសូត្រតាមរយៈការសិក្សាប្រវត្តិសាស្ត្រជាតិ ឬ ប្រវត្តិសាស្ត្រតំបន់។

### ៤.២.១ ទស្សនកិច្ចសិក្សា

ការដឹកនាំសិស្សឱ្យធ្វើការស្រាវជ្រាវរយៈពេលខ្លីទៅកាន់ទីកន្លែងណាមួយនៃតំបន់ប្រវត្តិសាស្ត្រ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសិក្សាទាំងឡាយដែលក្លឹបអាចធ្វើបាន។ ប្រាសាទបុរាណបានផ្ដល់ឱកាសច្រើនបំផុតសម្រាប់សកម្មភាពសិក្សាស្រាវជ្រាវនេះ ប៉ុន្តែយើងអាចសិក្សាពីអ្វីផ្សេងៗទៀត ដូចជាការទៅមើលសំណង់អគារចាស់ៗដែលនៅសេសសល់ពីសម័យអាណានិគមបារាំង តំបន់សមរភូមិចាស់ៗ ឬសារមន្ទីរ (នៅភ្នំពេញ ឬសៀមរាប)។ សិស្សគួរសិក្សាស្រាវជ្រាវពីទីកន្លែងណាមួយ ព្រមទាំងបញ្ចេញមតិយោបល់ពីសកម្មភាពដែលពួកគេចង់ធ្វើមុនពេលធ្វើដំណើរទៅកន្លែងនោះ។ គ្រូដឹកនាំក្លឹប ត្រូវធ្វើគម្រោងផែនការសកម្មភាពជាមួយសមាជិកក្លឹប។ មុនពេលឱ្យសិស្សស្រាវជ្រាវនៅកន្លែងណាមួយ គ្រូគួរសុំការអនុញ្ញាតពីឪពុកម្ដាយរបស់ពួកគេដើម្បីឱ្យពួកគាត់បានដឹងព័ត៌មានជាមុន។ ខាងក្រោមនេះ ជាសេចក្ដីអធិប្បាយពីអ្វីដែលត្រូវធ្វើនៅពេលចុះទៅមើលប្រាសាទ សំណង់អគារចាស់ៗ ឬកន្លែងប្រវត្តិសាស្ត្រផ្សេងៗ។

### កិច្ចការទី១៖ កាលបរិច្ឆេទសំណង់អគារ

ចំពោះអគារដែលនៅសល់ពីសម័យបារាំង ជាធម្មតាវាតែងមានសសរជាគោលដែលបង្ហាញពីកាលបរិច្ឆេទ រីឯប្រាសាទបុរាណវិញមានការលំបាកក្នុងការមើលកាលបរិច្ឆេទ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយមានវិធីមួយដែលអាចធ្វើឱ្យយើងដឹងបានពីកាលបរិច្ឆេទរបស់វា គឺការពិនិត្យមើលអក្សរសិលាចារិក។ ទោះជាយើងមិនអាចអានអក្សរនោះក៏ដោយ ក៏យើងអាចផ្ទួផ្ទងអក្សរមួយតួ ឬពីរតួ ជាមួយនឹងចំណែកថ្នាក់អក្សរសម័យបច្ចុប្បន្ន។ ឧទាហរណ៍ នៅក្នុងអក្សរសិលាចារិកខាងក្រោមដែលយកមកពីប្រាសាទភ្នំហាន់ជ័យក្នុងខេត្តកំពង់ចាម យើងឃើញថាអក្សរទីមួយ ដូចជាពាក្យ «សា»។

ការប្រើប្រាស់តារាងខាងក្រោមនេះ មានសារៈសំខាន់ណាស់សម្រាប់កំណត់កាលបរិច្ឆេទប្រាសាទបុរាណនៅកម្ពុជា ហើយបើទោះបីជាអ្នកមិនអាចអានអក្សរបុរាណលើសិលាចារិកទាំងនោះ (ជាទូទៅសរសេរជាភាសាសំស្ក្រឹត និងប្រើអក្សរខ្មែរបុរាណ) ក៏ដោយ ក៏អ្នកអាចកំណត់កាលបរិច្ឆេទប្រាសាទតាមសម័យកាលដោយផ្ទួផ្ទងប្រភេទអក្សរទៅនឹងលក្ខណៈខុសប្លែកគ្នារបស់វាដែលបានបង្ហាញក្នុងតារាងខាងក្រោម៖

ដោយយោងតាមតារាងនេះបានបង្ហាញថាមានសម័យធំៗ៤ គឺ៖

1. សម័យមុនអង្គរ (មុនសតវត្សរ៍ទី៩)
2. សម័យអង្គរ ( សតវត្សរ៍ទី៩ ដល់ សតវត្សរ៍ទី១៥)៖ មានអក្សរ ៥ប្រភេទ ក្នុងសម័យនោះ
3. សម័យក្រោយអង្គរ ឬ សម័យកណ្តាល ( សតវត្សរ៍ទី១៥ ដល់ សតវត្សរ៍ទី១៧)
4. សម័យបច្ចុប្បន្ន (សតវត្សរ៍ទី១៨ ដល់ បច្ចុប្បន្ន)

**តារាងអក្សរក្រមភាសាខ្មែរបុរាណ**

**CHARACTER SET OF ANCIENT KHMER SCRIPT**



| ភាសារ៉ូម៉ាំង | សម័យមុនអង្គរ | សម័យអង្គរ | | | | សម័យក្រោយអង្គរ | បច្ចុប្បន្ន | |
|---|---|---|---|---|---|---|---|---|
| | | ប្រភេទ ១ | ប្រភេទ ២ | ប្រភេទ ៣ | ប្រភេទ ៤ | | អក្សរមូល | អក្សរជ្រៀង |
| ṭha | ឋ | | | | | | ឋ | ឋ |
| ḍa | | ឌ | ឌ | ឌ | ឌ | ឌ | ឌ | ឌ |
| ḍha | ឍ | | | | | | ឍ | ឍ |
| ṇa | ណ ណ | ណ | ណ | ណ | ណ | ណ | ណ | ណ |
| ta | ត | ត | ត | ត | ត | ត | ត | ត |
| tha | ថ | ថ | ថ | ថ | ថ | ថ | ថ | ថ |
| da | ទ | ទ | ទ | ទ | ទ | ទ | ទ | ទ |
| dha | ធ ធ | ធ | ធ | ធ | ធ | ធ | ធ | ធ |
| na | ន | ន | ន | ន | ន | ន | ន | ន |
| pa | ប | ប | ប | ប | ប | ប | ប | ប |
| pha | ផ | ផ | ផ | ផ | ផ | ផ | ផ | ផ |
| ba | ព | ព | ព | ព | ព | ព | ព | ព |
| bha | ភ | ភ | ភ | ភ | ភ | ភ | ភ | ភ |
| ma | ម | ម | ម | ម | ម | ម | ម | ម |

| រូបរាង | មុនអង្គរ | សម័យអង្គរ | | | | កណ្ដាល | បច្ចុប្បន្ន | |
|---|---|---|---|---|---|---|---|---|
| | | អ ១ | អ ២ | អ ៣ | អ ៤ | | មូល | |
| ya | យ | យ | យ | យ | យ | យ | យ | យ |
| ra | រ | រ រ | រ រ | រ | រ រ | រ | រ | រ |
| la | ល ល | ល | ល | ល | ល | ល | ល | ល |
| va | វ | វ | វ | វ | វ | វ | វ | វ |
| śa/ça | ឝ | ឝ | ឝ | ឝ | ឝ | ឝ | ឝ | ឝ |
| ṣa | ឞ | ឞ | ឞ | ឞ | ឞ | ឞ | ឞ | ឞ |
| sa | ស | ស | ស | ស | ស | ស | ស | ស |
| ha | ហ | ហ | ហ | ហ | ហ | ហ | ហ | ហ |
| ḷa | | | | | | ឡ | ឡ | ឡ |
| a | អអអអ | អ | អ | អ | អ | អ | អ | អ |

# តារាងសំខ្យាសំព្ទបុរាណ

## ANCIENT NUMBER

| | មុនអង្គរ | សម័យអង្គរ | | | | កណ្ដាល | បច្ចុប្បន្ន |
|---|---|---|---|---|---|---|---|
| រ៉ូម៉ាំង | ម.អ. | អ.១ | អ.២ | អ.៣ | អ.៤ | អ.៥ | មូល |
| 0 | • | • | • | • | • | ៰ | 0 |
| 1 | I | I ១ | I ១ | I ១ | I ១ | ១ | ១ |
| 2 | II | II ២ | II ២ | II ២ | II ២ | ២ | ២ |
| 3 | III | III ៣ | III ៣ | III ៣ | III ៣ | ៣ | ៣ |
| 4 | IIII ៤ | IIII ៤ | IIII ៤ | IIII ៤ | IIII ៤ | ៤ | ៤ |
| 5 | IIIII ៥ | IIIII ៥ | IIIII ៥ | IIIII ៥ | IIIII ៥ | ៥ | ៥ |
| 6 | IIIIII ៦ ៦ | ៦ | ៦ | ៦ | ៦ | ៦ | ៦ |
| 7 | IIIIIII ៧ | ៧ | ៧ | ៧ | ៧ | ៧ | ៧ |
| 8 | IIIIIIII ៨ | ៨ | ៨ | ៨ | ៨ | ៨ | ៨ |
| 9 | IIIIIIIII ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ |
| 10 | IIIIIIIIII ጸ | ጸ ១. | ጸ ១. | + ១. | X ១. | ១០ | ១០ |
| 11 | ጸI | ጸI ១១ | ጸI ១១ | +I ១១ | XI ១១ | ១១ | ១១ |
| 12 | ጸII | ጸII ១២ | ጸII ១២ | +II ១២ | XII ១២ | ១២ | ១២ |
| 13 | ጸIII | ጸIII១៣ | ጸIII ១៣ | +III ១៣ | XIII ១៣ | ១៣ | ១៣ |

យើងឃើញថា ទម្រង់អក្សរនេះសមនឹងអក្សរដែលគេប្រើនៅមុនសម័យអង្គរ ហេតុដូចនេះ យើងអាចសន្និដ្ឋានបានថា ប្រាសាទនោះពិតជាត្រូវបានកសាងឡើងក្នុងសម័យអង្គរ ឬ មុនសតវត្សរ៍ទី៩។ កិច្ចការមួយក្នុងចំណោមកិច្ចទាំងឡាយដែលគ្រូត្រូវធ្វើ គឺត្រួតពិនិត្យមើលកាលបរិច្ឆេទដែលបញ្ជាក់ពីរយៈពេលខុសគ្នាក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងតារាងអក្សរដែលផ្តល់ឱ្យនៅក្នុង**ឧបសម្ព័ន្ធទី៥**។ ការសរសេរឈ្មោះនរណាម្នាក់ជាអក្សរបុរាណ ក៏អាចចាត់ទុកថាជាការធ្វើលំហាត់ដែលធ្វើឱ្យមានភាពសប្បាយរីករាយសម្រាប់សិស្សផងដែរ។

**គំនូសទី១៖ គំរូអក្សរសិលាចារិកសម័យបុរាណស្រង់ចេញពីប្រាសាទភ្នំហាន់ជ័យ**




**កិច្ចការទី២៖ ការផ្តានអក្សរតាមជញ្ជាំង**

ពេលធ្វើទស្សនកិច្ចនៅតាមប្រាសាទបុរាណ ការងារដែលគួរឱ្យចាប់អារម្មណ៍មួយទៀតគឺយកក្រដាសនិងខ្មៅដៃ ដើម្បីឱ្យសិស្សអាចសរសេរផ្តានអក្សរសិលាចារិកនោះ ប៉ុន្តែត្រូវសុំការអនុញ្ញាតពីអាជ្ញាធរ ឬអ្នកគ្រប់គ្រងដែលអាស្រ័យនៅទីនោះជាមុនសិន ដើម្បីជៀសវាងមានបញ្ហានៅពេលដំណើរការ។ អក្សរដែលបានផ្តិតនេះ អាចយកមកបង្ហាញដល់សិស្សផ្សេងៗទៀតដោយចាត់ទុកថាជាផ្នែកមួយនៃការតាំងពិព័រណ៍របស់ក្លឹប។

**កិច្ចការទី៣៖ ការគូសផែនទី**

ការគូសផែនទីប្រាសាទ ឬ ទីកន្លែងមួយ ក៏ជាលំហាត់ដែលមានសារៈប្រយោជន៍ផងដែរក្នុងការជួយឱ្យសិស្សគ្រប់ៗគ្នាបានយល់ពីភាពល្អប្រណីតនៃប្រវត្តិសាស្ត្រនៅកន្លែងនោះ។ ការគូសផែនទីអំពីទ្រង់ទ្រាយប្រាសាទបុរាណនៅកន្លែងណាមួយអាចបង្ហាញយើងច្រើនពីជំនឿ និងទំនៀមទម្លាប់កាលពីសម័យបុរាណ។ ឧទាហរណ៍ ប្រាសាទជាធម្មតាមានការរចនាតាមរបៀបដែលតំណាងឱ្យទេវកថាសាសនាហិណ្ឌូពីបុរាណ

ដែលគេមានជំនឿថាភ្នំសុមេរុ (Mt. Meru) ជាចំណុចកណ្តាលនៃពិភពលោក។ កំពូលប្រាសាទអង្គរវត្ត តំណាងឱ្យភ្នំសុមេរុ (Mt. Meru) ហើយគូរទឹកដែលគេជីកជុំវិញប្រាសាទតំណាងឱ្យមហាសមុទ្រដែលព័ទ្ធជុំវិញពិភពលោក នេះបើគិតតាមជំនឿសាសនាហិណ្ឌូកាលពីបុរាណ។ លើសពីនេះទៅទៀត ក្លោងទ្វារកណ្តាលនៃប្រាសាទជាធម្មតាបែរមុខទៅទិសខាងកើត ប៉ុន្តែមានក្លោងទ្វារប្រាសាទមួយ(ប្រាសាទអង្គរវត្ត) បែរមុខទៅទិសខាងលិច ហើយការបែរមុខទៅទិសខាងលិចនេះ គឺជាភាពល្អគ្មានពីរក្នុងចំណោមប្រាសាទទាំងឡាយ។ ការគូសផែនទីនៃទីតាំងសមរភូមិ ក៏ជាលំហាត់មួយដែលគួរឱ្យចាប់អារម្មណ៍ផងដែរ ដែលអាចនិយាយរៀបរាប់រឿងរ៉ាវបានយ៉ាងច្រើនពីព្រឹត្តការណ៍ដែលកើតមានឡើង។ នៅក្នុងសម័យអាណានិគមបារាំង ម៉ូដអគារអាចបង្ហាញយើងយ៉ាងច្រើនពីគោលគំនិតរបស់វិស្វករបារាំងនាសតវត្សរ៍ទី១៩។ ឧទាហរណ៍ សំណង់អគារក្នុងខេត្តកំពង់ចាមមានលំនាំប្លង់ដែលជាន់ខាងលើស្អាតជាងជាន់ខាងក្រោម។ ការស្រាវជ្រាវបែបនេះធ្វើឱ្យយើងដឹងពីទ្រង់ទ្រាយអគារដែលមាននៅខេត្តផ្សេងៗទៀត ដូចជាខេត្តបាត់ដំបង និងទីក្រុងភ្នំពេញ។

**កិច្ចការទី៤៖ ការស្រាវជ្រាវប្រវត្តិពិត និងរឿងព្រេងទាក់ទងនឹងទីកន្លែង**

នៅមុនពេលធ្វើទស្សនកិច្ចទៅកន្លែងណាមួយ សិស្សគួរស្វែងយល់ពីប្រវត្តិកន្លែងនោះជាមុនសិន។ ទាក់ទងនឹងប្រាសាទ ជួនកាលយើងស្រាវជ្រាវដឹងដោយការសួរព្រះសង្ឃ ឬចាស់ព្រឹទ្ធាចារ្យ។ នៅមានសៀវភៅល្អៗជាច្រើនដែលបានរៀបរាប់ពីទីកន្លែងទាំងនោះ ហើយសៀវភៅទាំងនោះអាចរកបានក្នុងបណ្ណាល័យរបស់សាលា (ឧ. សៀវភៅមានចំណងជើងថា *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា* និពន្ធដោយលោក មីសែល ត្រាណេ (Michel Tranet)។ ឧទាហរណ៍ ប្រាសាទនគរបាជ័យដែលស្ថិតក្នុងខេត្តកំពង់ចាមមានភាពល្បីល្បាញដែលបានកសាងឡើងដោយស្តេចមួយអង្គ ក្នុងគោលបំណងសុំខមាទោសដល់ទង្វើដែលខ្លួនបានសម្លាប់ព្រះបិតារបស់ខ្លួន និងរៀបអភិសេកជាមួយនឹងព្រះមាតារបស់ខ្លួននោះ។ ប្រាសាទជើងព្រៃនៅក្នុងស្រុកបាធាយ ខេត្តកំពង់ចាម បានកសាងឡើងដោយមានកំពូលខ្ពស់ដូចទៅនឹងប្រាសាទអង្គរវត្ត។ នៅក្នុងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ មានប៉មនាឡិកាចាស់មួយស្ថិតនៅតាមដងទន្លេមេគង្គ ដែលបាន កសាងដោយបារាំងដើម្បីត្រួតពិនិត្យចរាចរណ៍ផ្លូវទឹក និងពាណិជ្ជកម្មដែលជាមធ្យោបាយមួយកាលពីសតវត្សរ៍មុន។ ស្រដៀងគ្នានេះដែរ សិស្សអាចធ្វើការស្រាវជ្រាវនៅតាមទីកន្លែងផ្សេងៗរួមមានទីតាំងសមរភូមិ វិហារសាសនា ឬ ទីកន្លែងប្រវត្តិសាស្ត្រថ្មីៗដូចជា វាលពិឃាដ ជាដើម។

**កិច្ចការទី៥៖ ការស្រាវជ្រាវរចនាបថចម្លាក់ ឬស្ថាបត្យកម្ម**

កិច្ចការសំខាន់មួយផ្សេងទៀតដែលសិស្សអាចធ្វើការស្រាវជ្រាវបាន គឺការឈ្វេងយល់ពីគោលគំនិតសំណង់ប្រាសាទ ថាតើវាត្រូវបានកសាងឡើងតាមរចនាបថអ្វី។ ឧទាហរណ៍ ប្រាសាទនគរបាជ័យបានកសាងដោយថ្មភក់ពណ៌ខ្មៅ ដែលនេះជាសម្ភារៈសំណង់មានលក្ខណៈខុសប្លែកពីធម្មតាក្នុងសម័យនោះ និងមួយចំណែកទៀតគឺបញ្ជាក់ពីភាពល្អអស្ចារ្យគ្មានពីរ។ ជាធម្មតា ប្រាសាទដែលកសាងដោយថ្មភក់ពណ៌ខ្មៅ គឺជា

ប្រាសាទដែលបង្ហាញពីទឹកដៃដ៏ប៉ិនប្រសប់របស់អ្នកកសាង។ ព្រមជាមួយគ្នានេះដែរ សិស្សក៏អាចរាប់ចំនួនរូបគំនូរ និងការពណ៌នារបស់រូបគំនូរទាំងនោះ (រូបគំនូរបរិយាយពីរឿងព្រះពុទ្ធ រឿងទេវកថាសាសនាហិណ្ឌូ ។ល។) ហើយប្រសិនបើយើងមានម៉ាស៊ីនថតរូបមួយវាពិតជាល្អ និងមានប្រយោជន៍ខ្លាំងណាស់។ ចំពោះសំណង់អគារចាស់ៗជំនាន់បារាំងវិញ សិស្សអាចព្យាយាមស្វែងយល់ពីភាពទាក់ទាញអារម្មណ៍ និងភាពល្អឥតផ្ចឹមរបស់វា ដូចជាការរចនាទ្វារដែលមានលក្ខណៈកោង ការប្រកក្បឿងទល់មុខគ្នា និងមានការរចនាប្រកបដោយភាពសមស្របគ្នា។

**៤.២.២ សកម្មភាពស្រាវជ្រាវប្រវត្តិសាស្ត្រតាមរយៈសម្ភាសន៍**

ការធ្វើបទសម្ភាសជាមួយចាស់ព្រឹទ្ធាចារ្យនៅក្នុងតំបន់ណាមួយ គឺជាវិធីសាស្ត្រដ៏សំខាន់ដើម្បីស្វែងរកប្រវត្តិទីកន្លែងនោះ។ សិស្សក្នុងក្លឹបគួរតែពិនិត្យមើលប្រធានបទមួយដែលគួរឱ្យចាប់អារម្មណ៍ ហើយត្រូវស្រាវជ្រាវរកព័ត៌មានបន្ថែមទៀតដោយធ្វើការជជែកសួរជាមួយចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃ និងអ្នកដែលដឹងរឿងរ៉ាវទីកន្លែងប្រវត្តិសាស្ត្រនោះ។ ការធ្វើបទសម្ភាស គួរសរសេរជារបាយការណ៍ខ្លីៗប្រហែលជា ២ ទៅ ៥ ទំព័រ ដែលនិយាយពីការស្រាវជ្រាវ ហើយរបាយការណ៍នោះទៀតសោតគួរមានរូបគំនូរ រូបភាព និងដ្យាក្រាមផ្សេងៗស្របតាមស្ថានការណ៍ចាំបាច់។ នៅខាងក្រោមនេះ គឺជាប្រធានបទគួរចាប់អារម្មណ៍មួយចំនួនដែលក្លឹបគួរធ្វើការស្រាវជ្រាវ៖

**កិច្ចការទី១៖ ឈ្មោះទីកន្លែង**

គ្រប់ភូមិឃុំទាំងអស់នៅក្នុងប្រទេសកម្ពុជា មានឈ្មោះគួរឱ្យចាប់អារម្មណ៍ ហើយឈ្មោះទាំងនោះសុទ្ធតែមានប្រវត្តិរឿងរ៉ាវរបស់វា។ ឧទាហរណ៍ ហេតុអ្វីបានជាគេហៅថា **ស្វាយធំ ព្រៃឈរ ជើងព្រៃ** យើងគួរមានសំណួរខ្លះៗទាក់ទងនឹងឧទាហរណ៍ទាំងនេះ ដូចជា ភូមិ**ស្វាយធំ** វាហាក់បីដូចជាភូមិនោះត្រូវបានគេដាក់ឈ្មោះបន្ទាប់ពីមានដើមស្វាយមួយដើម ដែលធំអស្ចារ្យជាងគេហើយមើលទៅ សិស្សអាចសួរថា តើដើមស្វាយនោះដុះនៅត្រង់ណា? មានអាយុកាលប៉ុន្មានឆ្នាំហើយ? នរណាជាអ្នកដាំវា? គេកាប់វាចោលនៅពេលណា? ហេតុអ្វីបានគេកាប់វាចោល? គេកាប់ចោលប៉ុន្មានឆ្នាំហើយ? នរណាកាប់វាចោល?។ល។ ទាំងនេះគឺជាសំណួរសម្រាប់សិស្សធ្វើការស្រាវជ្រាវ និងសរសេរជារបាយការណ៍។ ក្នុងការប្រជុំក្លឹប និងមុនពេលសិស្សធ្វើទស្សនកិច្ចសិក្សា គ្រូត្រូវជួយសិស្សឱ្យគិតរកសំណួរបន្ថែមបន្ទាប់ពីសិស្សជ្រើសរើសយកប្រធានបទស្រាវជ្រាវណាមួយរួចរាល់។

**កិច្ចការទី២៖ ការកត់ត្រាពីការប្រែប្រួលទីកន្លែង**

ជាញឹកញាប់ការស្រាវជ្រាវពីពេលវេលា(កាលបរិច្ឆេទ)ធ្វើឱ្យយើងមានការលំបាក ឬដឹងដោយស្រពិចស្រពិល។ ប្រវត្តិសាស្ត្រ គឺជាការកត់ត្រាដ៏សំខាន់ពីព្រឹត្តិការណ៍ផ្លាស់ប្តូរនៅជុំវិញខ្លួនយើង និងដើម្បីឱ្យយើង

កាន់តែមានគំនិតល្អប្រសើរទាក់ទងនឹងការផ្លាស់ប្តូរទីកន្លែង និងដំណើរការផ្លាស់ប្តូររបស់វា។ ទោះបីជាយ៉ាងណាក៏ដោយ ប្រវត្តិទីកន្លែងមិនត្រូវបានគេសរសេរទុកទេ ដូច្នេះយើងត្រូវសួរម្ចាស់មូលដ្ឋានដែលគាត់នៅចាំពីរឿងរ៉ាវទាំងនោះ ដូចជាការកសាង ការបំផ្លាញ និងការប្រែប្រួល ជាដើម។ ប្រវត្តិសាលារៀនគឺជាប្រធានបទស្រាវជ្រាវដែលគួរឱ្យចាប់អារម្មណ៍ ពីព្រោះជាធម្មតាតែងមានគ្រូបង្រៀនដែលមានវ័យចំណាស់ ឬនាយកសាលាដែលគាត់នៅចាំថា តើសាលារៀននោះបានកសាងជាលើកឡើងនៅឆ្នាំណា? នរណាជានាយកសាលានាពេលនោះ? និងរឿងរ៉ាវផ្សេងៗទៀត។ រីឯគ្រូគួរតែជួយសិស្សឱ្យរកនឹកសរសេរសំណួរមុនពេលពួកគេទៅធ្វើការស្រាវជ្រាវនៅតាមទីកន្លែងជាក់ស្តែង។

**កិច្ចការទី៣៖ ការកត់ត្រាពីវត្ថុបុរាណ និងប្រពៃណីទំនៀមទម្លាប់ចាស់ៗ**

នៅក្នុងជីវភាពរស់នៅតែងមានការផ្លាស់ប្តូរជាប្រចាំនៅជុំវិញខ្លួនយើងយ៉ាងឆាប់រហ័ស ជាហេតុធ្វើឱ្យប្រពៃណី ទំនៀមទម្លាប់ និងរបៀបរបបធ្វើការងាររលុបបាត់។ ឧបករណ៍ប្រើប្រាស់ប្រពៃណីកាលពីសម័យបុរាណជាច្រើនត្រូវបានគេឈប់ប្រើ។ មនុស្សកាន់តែតិចទៅៗ ដែលបានប្រឹងប្រែងរៀនលេងឧបករណ៍តន្ត្រីបុរាណ ហើយទំនៀមទម្លាប់ប្រពៃណីសំខាន់ៗផ្សេងៗ ដូចជាអាពាហ៍ពិពាហ៍ ពិធីបុណ្យទានផ្សេងៗ មិនត្រូវបានគេយកមកអនុវត្តឱ្យដូចកាលពីដើមនោះទេ។ វាមានសារៈសំខាន់ណាស់ដែលសិស្សគួរជ្រើសរើសប្រធានបទណាមួយស្តីពីការប្រែប្រួលទំនៀមទម្លាប់ប្រពៃណី ហើយធ្វើការសិក្សាស្រាវជ្រាវជាមួយចាស់ព្រឹទ្ធាចារ្យក្នុងភូមិស្រុកខ្លួន។ ប្រធានបទស្រាវជ្រាវទាំងនោះរួមមាន ឧបករណ៍បុរាណសម្រាប់ធ្វើកសិកម្ម ឧបករណ៍នេសាទ ឧបករណ៍សម្រាប់ដឹកគាស់ក្នុងព្រៃ ឬរបៀបធ្វើបុណ្យទានកាលពីសម័យបុរាណ។ ការសិក្សាស្រាវជ្រាវទាំងនេះនឹងផ្តល់ឱកាសដល់សិស្សឱ្យចេះគូររូប និងសង់ដ្យាក្រាមបានច្រើន។

**កិច្ចការផ្សេងៗ៖**

គ្រូ និងសិស្ស អាចគិតគូរលើការជ្រើសរើសប្រធានបទផ្សេងៗក្រៅពីនេះមកធ្វើការសិក្សាស្រាវជ្រាវ រីឯប្រធានបទខាងលើ គឺគ្រាន់តែជាគំនិតមួយចំនួនប៉ុណ្ណោះ។

**៤.២.៣ ការតាំងពិព័រណ៍ស្នាដៃក្នុងបណ្ណាល័យ និងថ្នាក់រៀន**

គម្រោងប្រវត្តិសាស្ត្រដ៏គួរឱ្យចាប់អារម្មណ៍មួយទៀតសម្រាប់ក្លឹបនោះគឺ ការរៀបចំតាំងពិព័រណ៍ ដែលធ្វើឱ្យប្រវត្តិសាស្ត្រកាន់តែមានភាពទាក់ទាញចិត្តមនុស្សទាំងឡាយ ហើយនឹងអាចប្រាប់ឱ្យដឹងពីព្រឹត្តិការណ៍សំខាន់ៗ ដែលបានកើតមានឡើងនៅក្នុងតំបន់ណាមួយ ឬនៅក្នុងប្រទេសទាំងមូល។ ការតាំងពិព័រណ៍នេះអាចរៀបចំក្នុងបណ្ណាល័យ បន្ទប់រៀន ឬនៅក្នុងទីធ្លាបរិវេណសាលា។ ក្លឹបអាចរៀបចំការតាំងពិព័រណ៍ ២ ឬ ៣ ឬច្រើនតាមចំនួនសមាជិកក្នុងក្រុម។ ទោះជាយ៉ាងណាក៏ដោយ មានការណែនាំថា សូមឱ្យសិស្សរៀបចំការតាំងពិព័រណ៍ជាក្រុមដើម្បីសន្សំពេលវេលា ពីព្រោះមានការងារច្រើនណាស់នៅក្នុងសកម្មភាពនេះ ដូចជា ការ

គូសរូបភាព ការតុបតែងលម្អ ការស្រាវជ្រាវ ។ល។ ខាងក្រោមនេះ គឺជាគំនិតបំផុសមួយចំនួនសម្រាប់ការតាំងពិព័រណ៍៖

**ប្រធានបទទី១៖ ប្រភេទក្រដាសប្រាក់នៅក្នុងប្រវត្តិសាស្ត្រ**

ប្រភេទក្រដាសប្រាក់ខុសៗគ្នាដែលត្រូវបានគេប្រើក្នុងសម័យប្រវត្តិសាស្ត្រជាច្រើននៅប្រទេសកម្ពុជា ក៏ជាសញ្ញាមួយប្រាប់ពីរឿងរ៉ាវដ៏គួរឱ្យចាប់អារម្មណ៍ស្ដីពីការផ្លាស់ប្តូរក្នុងសង្គម។ សិស្សអាចស្រាវជ្រាវរកគំរូបិយប័ណ្ណ ក្នុងអំឡុងសម័យកាលនីមួយៗ (ឬទិញក្រដាសប្រាក់នោះពីទីផ្សារ) ហើយបង្កើតជាតារាងមួយដែលពណ៌នាពីរដ្ឋាភិបាលនាសម័យកាលនោះ ឆ្នាំដែលក្រដាសប្រាក់នៅមានការប្រើប្រាស់ ឬព្រឹត្តិការណ៍សំខាន់ៗដែលកើតឡើងក្នុងពេលនោះ។ សូមមើលក្នុង**ឧទាហរណ៍ខាងក្រោម**

ការតាំងពិព័រណ៍ក្នុងបណ្ណាល័យស្ដីពីប្រភេទប្រាក់តាមសម័យកាលខុសៗគ្នា

| ប្រភេទក្រដាសប្រាក់ | សម័យកាលប្រវត្តិសាស្ត្រ |
|---|---|
|  | ក្រដាស ប្រាំរៀល<br>សម័យរាជាណាចក្រកម្ពុជាលើកដំបូង<br>ឆ្នាំ១៩៥៤-១៩៧០ |
|  | ក្រដាស មួយរយរៀល<br>សម័យសាធារណរដ្ឋខ្មែរ<br>ឆ្នាំ១៩៧០-១៩៧៥ |

| | |
|---|---|
|  | ក្រដាស មួយរៀល<br>សម័យកម្ពុជាប្រជាធិបតេយ្យ<br>ឆ្នាំ១៩៧៥-១៩៧៩<br>(សម្គាល់៖ ប្រាក់ត្រូវបានបោះពុម្ព ប៉ុន្តែគ្មានចរាចរទេក្នុងសម័យកាលនោះ) |
|  | ក្រដាស ម្ភៃរៀល<br>សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា<br>ឆ្នាំ១៩៧៩-១៩៨៧ |

**ប្រធានបទទី២៖ ប្រភេទទង់ជាតិនៅក្នុងប្រវត្តិសាស្ត្រ**

ការតាំងពិព័រណ៌មួយទៀតស្តីពីទង់ជាតិ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងប្រភេទក្រដាសប្រាក់ខាងលើ ហើយសិស្សអាចស្រាវជ្រាវរកប្រភេទទង់ជាតិខុសៗគ្នា ពីសម័យកាលមួយទៅសម័យកាលមួយមកបង្ហាញ។

**ប្រធានបទទី៣៖ អក្សរបុរាណ**

ប្រធានបទនេះបានពីការធ្វើដំណើរទស្សនកិច្ចសិក្សាដែលបានបកស្រាយកាលពីទំព័រខាងដើម។ ការតាំងពិព័រណ៌រួមមាន ការផ្តិតយកអក្សរសិលាចារិក និងការពន្យល់បកស្រាយខ្លីៗពីកន្លែងថាតើការតាំងពិព័រណ៌នេះបានមកពីកន្លែងណា និងកើតមានឡើងក្នុងអំឡុងពេលណា។ ជាមួយគ្នានេះដែរសិស្សអាចផ្តល់ជាឧទាហរណ៍ខ្លះៗពីអក្សរសម័យបុរាណ និងបង្ហាញពីការផ្លាស់ប្តូរអក្សរ និងលេខទៅតាមសម័យកាលនីមួយៗ។

**ប្រធានបទទី៤៖ ការកំណត់ទីតាំងប្រាសាទ**

នេះគឺជាប្រធានបទមួយផ្សេងទៀតដែលបានមកពីការធ្វើដំណើរទស្សនកិច្ចសិក្សាតាមមូលដ្ឋាន។ សិស្សអាចកំណត់ពីទីតាំងប្រាសាទ និងគូសបញ្ជាក់ពីរូបភាពភូមិសាស្ត្រដែលនៅជុំវិញប្រាសាទ។ វាក៏មាន

ភាពគួរឱ្យចាប់អារម្មណ៍ផងដែរ នៅពេលសិស្សដាក់ខ្សែអំបោះពណ៌តាមទីកន្លែងក្នុងផែនទី (ឧ. ពីក្លោងទ្វារចូលទៅកាន់ប្រាសាទ បដិសណ្ឋានដ៏ពិសិដ្ឋ ។ល។) ជាមួយគ្នានេះដែរ ការតាំងពិព័រណ៍គួរមានរឿងនិទានស្ដីពីទីតាំងប្រាសាទ អាយុកាលរបស់ប្រាសាទ និងភាពទាក់ទាញអារម្មណ៍ពីសំណាក់ប្រាសាទនោះ។

**ប្រធានបទទី៥៖ ការគូសបង្ហាញពីពេលវេលា**

ការគូសបង្ហាញពីពេលវេលា គឺជាសោភណភាពមួយបញ្ជាក់ពីកាលបរិច្ឆេទដែលបង្ហាញពីព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើង។ ការបង្ហាញពីពេលវេលាគួរសរសេរចំណងជើងបញ្ជាក់ពីរយៈពេលក្នុងប្រវត្តិសាស្ត្រ។ ការពណ៌នាពីព្រឹត្តិការណ៍សំខាន់ៗត្រូវអមជាមួយនឹងរូបភាព ព្រមទាំងការពន្យល់បកស្រាយខ្លីៗពីអ្វីដែលបានកើតឡើង។ ចន្លោះពេលប្រវត្តិសាស្ត្រនៃព្រឹត្តិការណ៍នីមួយៗ គួរបញ្ជាក់ពីចំនួនឆ្នាំ។ ប្រវត្តិសាស្ត្រនៃព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងឆ្នាំ១៩៥៥ និងព្រឹត្តិការណ៍មួយទៀតដែលបានកើតឡើងក្នុងឆ្នាំ១៩៦៥ គួរតែពណ៌នាឱ្យបានវែងជាងពីរដងនៃព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងឆ្នាំ១៩៦៥ និងឆ្នាំ១៩៧០។ ការគូសបង្ហាញពេលវេលា អាចពណ៌នាពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាតិជាលំដាប់លំដោយ។ នេះជាឧទាហរណ៍ព្រឹត្តិការណ៍មួយចំនួនក្នុងប្រវត្តិសាស្ត្រក្នុងតំបន់ដែលអាចគូសជាដ្យាក្រាមបញ្ជាក់ពីពេលវេលាបាន៖

**ប្រវត្តិសាលារៀនរបស់ខ្ញុំពីឆ្នាំ១៩៣៦ ដល់ឆ្នាំ១៩៩៩**

- ✓ ១៩៣៦៖ សាលានេះកសាងដំបូងតាមរដ្ឋបាលបារាំង
- ✓ ១៩៤៥៖ សាលានេះបានខូចខាតដោយភ្លើងឆេះ ប៉ុន្តែបានកសាងឡើងវិញដោយថ្ម
- ✓ ១៩៥៦៖ សាលានេះបានកសាងបន្ថែមអគារ២ខ្នងទៀត
- ✓ ១៩៦៥៖ សាលានេះបានប្រែក្លាយទៅជាសាលាមធ្យមសិក្សា
- ✓ ១៩៧៣៖ សាលានេះបានខូចខាតម្ដងទៀតដោយសារការទម្លាក់គ្រាប់បែក
- ✓ ១៩៧៩៖ សាលានេះបានកសាងឡើងវិញដោយសហគមន៍មូលដ្ឋាន ប៉ុន្តែធ្វើដោយឈើ
- ✓ ១៩៩៣៖ សាលានេះបានយកធ្វើជាស្ថានីយបោះឆ្នោត អំឡុងពេលបោះឆ្នោតជាតិលើកដំបូងនៅកម្ពុជា
- ✓ ១៩៩៩៖ សាលានេះបានពង្រីកពេលដែលរដ្ឋាភិបាលកសាងអគារថ្មីធ្វើពីថ្មចំនួន ២ខ្នងទៀត

**ប្រធានបទទី៦៖ ឧបករណ៍ ឬវត្ថុបុរាណជាប្រវត្តិសាស្ត្រ**

សកម្មភាពស្រាវជ្រាវប្រវត្តិសាស្ត្រផ្ទាល់មាត់ អាចជួយបង្កើតឱ្យមានការតាំងពិព័រណ៍ពីឧបករណ៍ដែលមានអាយុកាលចំណាស់ដែលមនុស្សប្រើសម្រាប់ធ្វើស្រែចំការ ឬប្រមាញ់។ ការតាំងពិព័រណ៍នោះត្រូវមានរូបភាពដ៏គួរឱ្យចាប់អារម្មណ៍នៃឧបករណ៍អមជាមួយនឹងអត្ថបទបកស្រាយ។ ប្រសិនបើការតាំងពិព័រណ៍ធ្វើនៅកន្លែងដែលមានសុវត្ថិភាព យើងអាចតាំងបង្ហាញឧបករណ៍ ឬ វត្ថុបុរាណទាំងអស់នោះ។

### ប្រធានបទទី៧៖ ដ្យាក្រាមគ្រួសារ

ព្រមជាមួយគ្នានេះ សិស្សអាចធ្វើការសិក្សាស្រាវជ្រាវពីគ្រួសាររាជវង្សសំខាន់ណាមួយក្នុងប្រវត្តិសាស្ត្រកម្ពុជា ហើយបង្កើតជាដ្យាក្រាមគ្រួសារមួយដែលបង្ហាញពីទំនាក់ទំនងរវាងស្តេចអង្គនីមួយៗស្របតាមប្រវត្តិសាស្ត្រខុសៗគ្នា។ សូមមើលឧទាហរណ៍មួយស្តីពីដ្យាក្រាមពង្សាវលីព្រះបាទជ័យវរ្ម័នទី៧

**ដ្យាក្រាមពង្សាវលីព្រះបាទជ័យវរ្ម័នទី៧**




### ៤.២.៤ ការអញ្ជើញវាគ្មិន

យើងក៏អាចអញ្ជើញចាស់ព្រឹទ្ធាចារ្យឱ្យមកជួបក្រុមសិស្ស ដោយបរិយាយពីបទពិសោធដែលទាក់ទងនឹងប្រវត្តិសាស្ត្រមូលដ្ឋាន។ ព្រះសង្ឃ ឬព្រឹទ្ធាចារ្យ ជាមនុស្សដែលសក្តិសមជាងគេក្នុងការមកទស្សនាសាលារៀនក្នុងឋានៈជាភ្ញៀវដែលអាចបរិយាយពីប្រវត្តិអ្វីមួយបាន។ ប្រធានបទដែលអញ្ជើញពួកគាត់ឱ្យមកបរិយាយរួមមានដូចខាងក្រោម៖

### ប្រធានបទទី១៖ ស្ថានភាពរស់នៅក្រោមការគ្រប់គ្រងរបស់បារាំង

រឿងរ៉ាវពាក់ព័ន្ធនឹងជីវភាពរស់នៅដ៏គួរឱ្យចាប់អារម្មណ៍ជាច្រើន ក្នុងរយៈពេលមួយក្រោមការគ្រប់គ្រងរបស់បារាំង ដែលចាស់ៗអាចរៀបរាប់បាន។ ឧទាហរណ៍ មានការយកពន្ធតឹងរ៉ឹងដែលធ្វើឱ្យប្រជាជនកម្ពុជាបានធ្វើការតវ៉ាប្រឆាំងក្នុងអំឡុងពេលនោះ។ ប្រជាជនត្រូវបានគេបង្ខំឱ្យបង់ពន្ធថ្លៃសំលៀកបំពាក់យ៉ាងតឹងរ៉ឹង និងហាមមិនឱ្យស្លៀកពាក់ខោអាវដែលគ្មានស្លាកពន្ធនៅតាមទីសាធារណៈឡើយ។

### ប្រធានបទទី២៖ នៅពេលមានព្រៃឈើ

ផ្ទៃដីប្រទេសកម្ពុជាគ្របដណ្តប់ដោយព្រៃឈើយ៉ាងក្រាស់ ប៉ុន្តែព្រៃឈើជាច្រើនត្រូវបានគេកាប់ចោលអស់ក្នុងសម័យសង្គ្រាមក្នុងស្រុកដើម្បីរារាំងសកម្មភាពពួកប្រឆាំង។ ដូច្នេះយើងត្រូវអញ្ជើញចាស់ព្រឹទ្ធាចារ្យណាម្នាក់ ដើម្បីមកធ្វើការជជែកសួរនាំថាតើគេបានកាប់ព្រៃឈើនៅពេលណា? ព្រៃឈើទាំងអស់នោះកាលពីមុនវាដុះនៅឯណា? ហើយថាតើមានសត្វអ្វីខ្លះដែលធ្លាប់បានមករស់នៅក្នុងព្រៃនោះ?

### ប្រធានបទទី៣៖ ការអប់រំនៅកម្ពុជាពេលអតីតកាល និងបច្ចុប្បន្ន

វាជាប្រធានបទដែលមានសារៈប្រយោជន៍មួយក្នុងការជជែកពីការប្រែប្រួលការអប់រំនៅកម្ពុជា ក្នុងរយៈពេលជាង ៤០ ឬ ៥០ ចុងក្រោយនេះ។ នៅក្នុងពេលបច្ចុប្បន្ននេះ យើងឃើញមានសាលារៀនជាច្រើនបើធៀបនឹងសាលារៀនដែលមានកាលពីទសវត្សឆ្នាំ១៩៥០ និងឆ្នាំ១៩៦០ ជាពិសេសគឺសាលាមធ្យមសិក្សា។ បើក្រឡេកទៅមើលសម័យអតីតកាល គឺមានសាលាមធ្យមសិក្សាតែមួយគត់នៅក្នុងខេត្តនីមួយៗ ហើយភាសាដែលបង្រៀននៅពេលនោះ គឺភាសាបារាំង មិនមែនភាសាខ្មែរនោះទេ។ លើសពីនេះទៅទៀត រចនាសម្ព័ន្ធប្រព័ន្ធអប់រំត្រូវបានផ្លាស់ប្តូរពីប្រព័ន្ធអប់រំរបស់បារាំង (ត្រង់ថា ថ្នាក់រៀនបញ្រ្ចាស់ពីសម័យនោះ គឺថ្នាក់ទី ១ សព្វថ្ងៃ ស្មើនឹងថ្នាក់ទី១២ នៃប្រព័ន្ធអប់រំចាស់របស់បារាំង) ឱ្យទៅជាប្រព័ន្ធអប់រំបែបអន្តរជាតិដែលប្រើពេល ៦ ឆ្នាំសម្រាប់សិក្សានៅកម្រិតបឋមសិក្សា និង ៦ឆ្នាំទៀតនៅកម្រិតមធ្យមសិក្សា។ សិស្សអាចសួរនាំអ្នកណាម្នាក់ដែលមានវ័យចំណាស់ ហើយមានចំណេះដឹងលើការអប់រំ (ឧ. នាយកសាលាដែលមានបទពិសោធ) ពីការផ្លាស់ប្តូរប្រព័ន្ធអប់រំទាំងផ្នែកប្រសិទ្ធភាព រចនាសម្ព័ន្ធ និងកម្មវិធីសិក្សា។

### ៤.២.៥ ការបង្កើតខិត្តប័ណ្ណផ្សព្វផ្សាយតំបន់មូលដ្ឋាន

ខិត្តប័ណ្ណគឺជាវិធីដ៏ល្អមួយដែលអាចដាក់បញ្ចូលព័ត៌មានងាយៗជាច្រើន ដើម្បីទាក់ទាញពីកន្លែងណាមួយ។ ខិត្តប័ណ្ណគឺជាសន្លឹកក្រដាសមួយដែលបត់ជាបីផ្នែកផ្សេងៗគ្នា។ សិស្សអាចផ្សព្វផ្សាយព័ត៌មានជាច្រើនដែលគួរឱ្យចាប់អារម្មណ៍សម្រាប់អ្នកមកទស្សនកិច្ចក្នុងមូលដ្ឋានរបស់ពួកគេ (ឧ. ម្ហូបតំបន់ ប្រាសាទបុរាណ តំបន់ទេសចរណ៍ធម្មជាតិ បុណ្យប្រពៃណីរបស់សហគមន៍។ល។)។ ចូរចាំថា ចំណុចសំខាន់ក្នុងខិត្តប័ណ្ណគឺធ្វើឱ្យអ្នកអានចង់មកទស្សនកិច្ចក្នុងមូលដ្ឋានរបស់យើង ដូចនេះវាពិតជាល្អប្រសិនបើយើងបន្ថែមដោយរូបភាពផ្ទាំងគំនូរ ដើម្បីធ្វើឱ្យវាមានភាពទាក់ទាញ។

### ៤.២.៦ ការផ្សារភ្ជាប់ក្លឹបជាមួយនឹងការរៀនសូត្ររបស់សិស្សដទៃទៀត

ទោះបីជាសិស្សទាំងអស់មិនមែនជាសមាជិករបស់ក្លឹបក៏ដោយ ក៏វាមានសារៈសំខាន់ក្នុងការដែលសមាជិកក្លឹប ចេះចែករំលែកបទពិសោធជាមួយនឹងសិស្សដទៃ។ សកម្មភាពមួយចំនួនដែលរៀបរាប់ខាងលើបានផ្តល់ឱកាសយ៉ាងពេញលេញដើម្បីចែករំលែកព័ត៌មានស្រាវជ្រាវពីប្រវត្តិសាស្ត្រដល់សិស្សដទៃទៀត ដូចជា ការដាក់តាំងពិព័រណ៍ និងការអញ្ជើញភ្ញៀវជាវាគ្មិនដែលអាចបរិយាយពីប្រវត្តិសាស្ត្រអ្វីមួយ។ វាក៏អាចធ្វើទៅបានផងដែរសម្រាប់សិស្សក្នុងថ្នាក់ដែលមិនមែនជាសមាជិកក្លឹបឱ្យចូលរួមក្នុងដំណើរការស្រាវជ្រាវ។ សមាជិកក្លឹប អាចត្រូវបានគេស្នើឱ្យដឹកនាំក្រុមក្នុងការបំពេញកិច្ចការដែលផ្តល់ឱ្យដូចបានរៀបរាប់កាលពីខាងដើម។ អ្នកដឹកនាំក្រុមអាចពន្យល់បកស្រាយដល់សិស្សផ្សេងៗទៀតពីអក្សរសិលាចារិក សារៈសំខាន់នៃទ្រង់ទ្រាយទីកន្លែងប្រវត្តិសាស្ត្រ ឬព្រឹត្តិការណ៍សំខាន់ៗមួយចំនួនដែលកើតឡើងនាពេលនោះ។

## ឧបសម្ព័ន្ធទី១៖ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស និងការតម្រង់ទិស

<u>**សេចក្ដីផ្ដើម៖**</u>

ការចូលរួមក្លឹបប្រវត្តិសាស្ត្រ ជាឱកាសមួយដើម្បីអនុវត្តសកម្មភាពគួរឱ្យចាប់អារម្មណ៍ទាក់ទងនឹងប្រវត្តិមូលដ្ឋានណាមួយ ហើយនេះជាចំណុចមួយចំនួនដែលសិស្សគួរដឹងមុនពេលសម្រេចចិត្តថាតើត្រូវចូលរួមក្លឹបឬមួយយ៉ាងណា៖

- **វត្ថុបំណង៖** ដើម្បីបង្កើនការយល់ដឹងរបស់សិស្សពីប្រវត្តិសាស្ត្រក្នុងមូលដ្ឋាន។
- **សកម្មភាព៖** ធ្វើដំណើរទស្សនកិច្ចសិក្សា ការតាំងពិព័រណ៍ប្រវត្តិសាស្ត្រ ការស្រាវជ្រាវជាក្រុមតាមរយៈសម្ភាសន៍ និងការអានសៀវភៅ ។ល។
- **ការវាយតម្លៃ៖** ពុំមានការវាយតម្លៃ ឬដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ គឺសិស្សចូលរួមក្នុងសកម្មភាពក្លឹបដោយការពេញចិត្តរបស់ពួកគេ ពុំមែនដោយសារការបង្ខំឡើយ។
- **ការចូលរួម៖** សមាជិកភាពក្លឹបចូលរួមដោយស្ម័គ្រចិត្ត។
- **ការប្រជុំ៖** ការប្រជុំសាមញ្ញ (ប្រហែល២សប្ដាហ៍ម្ដង) ដើម្បីពិភាក្សាពីសកម្មភាពដែលបានគ្រោងទុក។ ចំណុចខាងលើនេះ ត្រូវអនុវត្តក្រៅម៉ោងសិក្សា ឬថ្ងៃឈប់សម្រាក។

<u>**កម្រងសំណួរ៖**</u>

សូមបង្ហាញពីកម្រិតចាប់អារម្មណ៍របស់អ្នកពីការចូលរួមក្នុងក្លឹបប្រវត្តិសាស្ត្រដោយរើសយកប្រអប់តែមួយក្នុងចំណោមប្រអប់ទាំង៣ ខាងក្រោមនេះ៖

☐ ខ្ញុំគ្មានចំណាប់អារម្មណ៍សោះក្នុងការចូលរួមក្នុងក្លឹបប្រវត្តិវិទ្យានេះ។

☐ ខ្ញុំប្រហែលជាចាប់អារម្មណ៍ក្នុងការចូលរួមក្លឹបនេះ ប៉ុន្តែខ្ញុំមិនដឹងច្បាស់ថាតើខ្ញុំអាចមានពេលចូលរួមដែរឬទេ។

☐ ខ្ញុំចាប់អារម្មណ៍ក្នុងការចូលរួមក្លឹបនេះណាស់ ហើយខ្ញុំដឹងច្បាស់ថាខ្ញុំមានពេលដើម្បីចូលរួមក្លឹបនេះ។

ឧបសម្ព័ន្ធទី២៖ ការបែងចែកភារកិច្ច

- **<u>ប្រធាន</u>**
  - រៀបចំការប្រជុំក្លឹប
  - សម្របសម្រួលការរៀបចំរបៀបវារៈកិច្ចប្រជុំនីមួយៗ
  - សម្របសម្រួលការប្រជុំ
  - សម្របសម្រួលជាមួយនាយកសាលាដើម្បីជានាថាមានន្លែងសម្រាប់ប្រជុំ
  - បង្កើតសម្ព័ន្ធភាពរវាងក្លឹប និងគណៈកម្មការគ្រប់គ្រងសាលា
  - ត្រួតពិនិត្យការអនុវត្តផែនការប្រចាំត្រីមាស
  - រាយការណ៍ពីបញ្ហាទាំងឡាយដែលកើតឡើងដល់គ្រូដឹកនាំក្លឹប
- **<u>អនុប្រធាន</u>**
  - បំពេញតួនាទីជាប្រធានអង្គប្រជុំនៅពេលដែលប្រធានអវត្តមាន
  - ជួយសម្របសម្រួលកិច្ចប្រជុំ
  - កត់ត្រាកំណត់ហេតុ
- **<u>ហិរញ្ញិក</u>**
  - ទទួលខុសត្រូវលើថវិកាដែលគ្រូដឹកនាំបានផ្តល់ឱ្យសម្រាប់ធ្វើសកម្មភាពផ្សេងៗ រួមមានការទិញសម្ភារសម្រាប់ការតាំងពិព័រណ៍ និងការធ្វើដំណើរទស្សនកិច្ចសិក្សា។ល។
  - ថែរក្សាកំណត់ត្រាថវិកាទាំងអស់ដែលទទួលបានពីគ្រូដឹកនាំក្លឹប
  - ទិញ ឬចំណាយតាមការបង្ហាញរបស់គ្រូដឹកនាំក្លឹប
- **<u>ប្រធានក្រុម</u>**
  - ណែនាំពីការដឹកនាំក្រុម
  - ធ្វើរបាយការណ៍តំណាងក្រុមជូនដល់ប្រធានអង្គប្រជុំ ឬគ្រូដឹកនាំក្លឹប
  - ផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីប្រធានអង្គប្រជុំ ឬ គ្រូដឹកនាំក្លឹបដល់សមាជិកក្នុងក្រុម
- **<u>គ្រូដឹកនាំក្លឹប</u>**
  - ផ្តល់ការណែនាំដល់ក្លឹបក្នុងការបង្កើតផែនការ រៀបចំការប្រជុំជ្រើសរើសប្រធានក្លឹបដើម្បីឱ្យគាត់
  - អាចធ្វើការងារផ្សេងៗបានដោយខ្លួនឯង។
  - ជួយផ្នែកបច្ចេកទេសទាក់ទងនឹងក្លឹបប្រវត្តិសាស្ត្រ (មេរៀនស្តីពីអក្សរបុរាណ យុគសម័យប្រវត្តិសាស្ត្រនៅក្នុងប្រទេសកម្ពុជា។ល។
  - តំណាងក្លឹបចំពោះមុខគណៈកម្មការនៅពេលធ្វើប្រតិបត្តិការថវិកា។
  - សម្របសម្រួលសកម្មភាពផ្សេងៗដូចជា ការរៀបចំផែនការ និងការធ្វើដំណើរទស្សនកិច្ចសិក្សា។
  - សម្របសម្រួលផ្នែកទំនាក់ទំនងរវាងក្លឹប និងរដ្ឋបាលរបស់សាលានៅពេលមានសកម្មភាពផ្សេងៗ ដូចជា ការប្រើប្រាស់បណ្ណាល័យសម្រាប់ប្រជុំជាដើម។

- គ្រួតពិនិត្យធនធានថវិកាដែលក្លឹបប្រើប្រាស់។

## ឧបសម្ព័ន្ធទី៣៖ ការកំណត់ផែនការ

ត្រីមាសទី១

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| 1. | | | | | | | | | | | | |
| 2. | | | | | | | | | | | | |
| 3. | | | | | | | | | | | | |
| 4. | | | | | | | | | | | | |
| 5. | | | | | | | | | | | | |
| 6. | | | | | | | | | | | | |
| 7. | | | | | | | | | | | | |
| 8. | | | | | | | | | | | | |
| 9. | | | | | | | | | | | | |
| 10. | | | | | | | | | | | | |
| 11. | | | | | | | | | | | | |
| 12. | | | | | | | | | | | | |

ត្រីមាសទី២

| សកម្មភាព | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| 1. | | | | | | | | | | | | |
| 2. | | | | | | | | | | | | |
| 3. | | | | | | | | | | | | |
| 4. | | | | | | | | | | | | |
| 5. | | | | | | | | | | | | |
| 6. | | | | | | | | | | | | |
| 7. | | | | | | | | | | | | |
| 8. | | | | | | | | | | | | |
| 9. | | | | | | | | | | | | |
| 10. | | | | | | | | | | | | |
| 11. | | | | | | | | | | | | |
| 12. | | | | | | | | | | | | |

**ឧបសម្ព័ន្ធទី៤៖ ការកំណត់ធនធាន**

| ការចំណាយ | រូបមន្ត | ចំនួន |
|---|---|---|
| 1. ក្រដាសផ្ទាំងធំ | ១គក្រ x ២ដុល្លា/គក្រ | ២ដុល្លា |
| 2. ហ្វឺតសរសេរក្តារខៀន | ២ប្រអប់ x ២.៥០/ប្រអប់ | ៥ដុល្លា |
| 3. ក្រដាសពណ៌ | ២រ៉ាម x ៤ដុល្លា/រ៉ាម | ៨ដុល្លា |
| 4. ការបោះពុម្ពសំណេរ | ... | ១០ដុល្លា |
| 5. ការចុះមូលដ្ឋាន<br>អាហារថ្ងៃត្រង់<br>រថយន្តឈ្នួល<br>ម៉ាស៊ីនថតរូប | <br>១៥នាក់ x ១ដុល្លា/នាក់<br>២៥ដុល្លា/ថ្ងៃ x ១ថ្ងៃ<br>១កាមេរ៉ា x ៨ដុល្លា | <br><br>១៥ដុល្លា<br>២៥ដុល្លា<br>៨ដុល្លា<br>៤៨ដុល្លា |
| 6. ការចុះមូលដ្ឋាន<br>អាហារថ្ងៃត្រង់<br>រថយន្តឈ្នួល<br>ម៉ាស៊ីនថតរូប | <br>១៥នាក់ x ១ដុល្លា/នាក់<br>២៥ដុល្លា/ថ្ងៃ x ១ថ្ងៃ<br>១កាមេរ៉ា x ៨ដុល្លា | <br>១៥ដុល្លា<br>២៥ដុល្លា<br>៨ដុល្លា<br>៤៨ដុល្លា |
| **សរុប** | | **១២១ដុល្លា** |